# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មាន
## ស្តីពី
## យុទ្ធនាការជាតិ ក្រោមប្រធានបទ
## "រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩"

អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ (អ.ប.ទ) នៃគណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានចាប់ផ្តើមធ្វើយុទ្ធនាការជាតិក្រោមប្រធានបទ "រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩" ដែលបានប្រព្រឹត្តទៅនៅថ្ងៃចន្ទ ៨កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ ក្នុងគោលបំណងដើម្បីក្រើនរំលឹក ពង្រាក់ស្មារតី និងការបង្កើនជម្រុញការចូលរួមរបស់បុគ្គល គ្រួសារ និងសហគមន៍ ព្រមទាំងបងប្អូនប្រជាពលរដ្ឋ ស្ថាប័ន-ក្រសួងពាក់ព័ន្ធ អង្គភាពសាធារណៈដទៃទៀត អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ មន្ទីរ អង្គភាពជំនាញនានា អង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសេវាឯកជនទាំងអស់ ពួតដៃរួមគ្នាអនុវត្តវិធានការចាំបាច់ៗនានា ដែលបានដាក់ចេញដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់រាជរដ្ឋាភិបាល ក្រសួងសុខាភិបាល ស្ថាប័នពាក់ព័ន្ធនានា អង្គការជាតិ អន្តរជាតិ វិស័យឯកជន និងបងប្អូនប្រជាពលរដ្ឋទាំងអស់ នាពេលកន្លងមកនេះ បានរួមចំណែកក្នុងការទប់ស្កាត់ការរីករាលដាលនៃវីរុសកូវីដ-១៩ ជាពិសេសពួកបម្លែងថ្មី ដូចជា អាល់ហ្វា និងដែលតា ក្នុងកម្រិតណាមួយក្តី យើងក៏មិនត្រូវមានអារម្មណ៍ស្កប់ស្កល់និងអ្វីដែលជាសមិទ្ធផលដែលយើងទទួលបានយ៉ាងលំបាកនេះទេ យើងត្រូវតែរួបរួមគ្នាជាបន្តទៅទៀត ដើម្បីទប់ស្កាត់មិនឱ្យមានការឆ្លង និងបាត់បង់អាយុជីវិតជាបន្ថែមទៀត នៅក្នុងបរិបទនៃការប្រយុទ្ធជំងឺកូវីដ-១៩ នេះ។ អាស្រ័យហេតុនេះ យុទ្ធនាការជាតិថ្ងៃនេះ ដើម្បីជម្រុញលើកទឹកចិត្តលោកអ្នកទាំងអស់គ្នា ឱ្យប្រែក្លាយចំណេះដឹងអំពីវិធានការបង្ការជំងឺដ៏កាចសាហាវនេះ ជាពិសេសគឺវិធានការ "**៣ការពារ** ( ពាក់ម៉ាស់ លាងដៃឱ្យញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គលពីមួយម៉ែត្រកន្លះឡើង) និង**៣កុំ** (កុំទៅកន្លែងមានមនុស្សច្រើន កុំទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា)" ដែលបានដាក់ចេញឱ្យអនុវត្តតាំងពីពាក់កណ្តាលខែធ្នូ ឆ្នាំ២០២០ មកនេះ ឱ្យក្លាយទៅជាការអនុវត្តន៍ជាក់ស្តែងពិតប្រាកដបន្ថែមទៀត ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយផ្តើមចេញពីបុគ្គលផ្ទាល់ខ្លួនម្នាក់ៗ សមាជិកគ្រួសារ សហគមន៍ និងសង្គមទាំងមូល ដែលអនុញ្ញាតឱ្យយើងទាំងអស់គ្នាអាចបន្តអាជីវកម្ម និងប្រកបការងារលើគ្រប់វិស័យទាំងអស់ ព្រមទាំងអាចដំណើរការឡើងវិញបានជាបណ្តើរៗ ហើយប្រជាពលរដ្ឋអាចប្រកបរបររកស៊ីទទួលទានចិញ្ចឹមជីវិតឡើងវិញប្រកបដោយសុវត្ថិភាព នៅក្នុងបរិបទរៀនរស់ជាមួយនឹងវីរុសកូវីដ-១៩ តាមបែបរស់នៅធម្មតាក្នុងប្រក្រតីភាពថ្មី។

ជាទូទៅ ជំងឺរាតត្បាតកូវីដ-១៩ បាននិងកំពុងវាយលុកជាង១៣០ប្រទេសលើសកលលោក ក្នុងនោះ ក៏មានបណ្តាប្រទេសជាច្រើនដែលមានលក្ខណៈធូរស្បើយនាពេលកន្លងមក តែក៏មានការរាតត្បាតទ្រង់ទ្រាយធំឡើងវិញ ដោយសារតែការធ្វើចរាចរយ៉ាងទូលំទូលាយនៃ **វីរុសបំប្លែងថ្មីប្រភេទដែលតា B. 1. 617-2 (Delta)** ដែលរាលដាលក្នុងល្បឿនមួយលឿន



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ជាងវីរុសកូវីដ-១៩ប្រភេទផ្សេងៗទៀត ហើយក៏ជាប្រភេទវីរុសកូវីដ-១៩ ដែលសកលលោកទាំងមូលទទួលស្គាល់ថាងាយឆ្លងបំផុតនាពេលបច្ចុប្បន្ននេះ គួបផ្សំទៅនឹងការខ្វះចន្លោះនៃការអនុវត្តន៍វិធានការមិនប្រើឱសថ (Non-Phamaceutical Interventions (NPIs)ផងដែរ។ ទោះបីជាប្រទេសកម្ពុជាយើងមានសញ្ញានៃការថយចុះនូវការចម្លង និងការស្លាប់នៅតាមខេត្តខ្លះក្តី ហានិភ័យនៃការកើនឡើងនៃករណីជំងឺកូវីដ-១៩ ដោយសារតែវីរុសកូវីដ-១៩ ប្រភេទដែលតា គឺមានខ្ពស់ណាស់។ នេះមានន័យថា ជំងឺរាតត្បាតកូវីដ-១៩ នៅឆ្ងាយពីទីបញ្ចប់ ហើយជាក់ស្តែង គិតចាប់ពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ កម្ពុជាបានរកឃើញអ្នកមានវិជ្ជមានវីរុសកូវីដ-១៩ ប្រភេទ ដែលតា (Delta) លើពលករត្រលប់ពីប្រទេសថៃ និងប្រទេសវៀតណាម អ្នកដំណើរមកតាមជើងហោះហើរ បុគ្គលិកសុខាភិបាល មន្ត្រីរាជការ និងអ្នកភូមិនៅក្នុងសហគមន៍ សរុបទាំងអស់ចំនួន ៤៩៤នាក់ (ស្ត្រី ២៤៣នាក់) និងបានប៉ះពាល់ដល់បណ្តា ២២ រាជធានី-ខេត្តរួចទៅហើយ លើកលែងតែខេត្តចំនួន ៣ ប៉ុណ្ណោះ គឺ ខេត្តកែប ខេត្តតាកែវ និងខេត្តក្រចេះ ដែលនៅមិនទាន់មានរបាយការណ៍ពីករណីដែលតានេះនៅឡើយ។ យោងតាមលទ្ធផលខាងលើនេះ បង្ហាញឱ្យយើងឃើញថា ប្រសិនបើមានការធ្វេសប្រហែស វីរុសដែលតា **(Delta)** នឹងបន្តរាតត្បាតវាយលុកចូលក្នុងសហគមន៍របស់យើង ជាពិសេសរាជធានីភ្នំពេញ ខេត្តឧត្តរមានជ័យ សៀមរាប ព្រះវិហារ កំពង់ចាម កំពង់ធំ និងបណ្តាខេត្តមួយចំនួនទៀត ដែលទាមទារឱ្យមានវិធានការរួមផ្សំគ្នាជាច្រើន និងទាមទារឱ្យមានការរួបរួមគ្នា ដើម្បីអាចទប់ស្កាត់ការចម្លងនេះបាន។

ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩ សូមអំពាវនាវយ៉ាងឱឡារិក ដល់សាធារណៈជន និងបងប្អូនប្រជាពលរដ្ឋទាំងអស់ ដូចតទៅ៖

**ក. សម្រាប់ បុគ្គល គ្រួសារ និង បងប្អូនប្រជាពលរដ្ឋទាំងអស់នៅទូទាំងប្រទេសកម្ពុជា៖**

- សូមចូលរួមបន្តផ្សព្វផ្សាយ ចំណេះដឹង អំពីវិធានការណ៍បង្ការ **៣ការពារ** និង**៣កុំ** ឱ្យទៅជាការអនុវត្តន៍ជាក់ស្តែងជាប្រចាំ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយផ្តើមចេញពីបុគ្គលផ្ទាល់ខ្លួនម្នាក់ៗ សមាជិកគ្រួសារ សហគមន៍ និងសង្គមទាំងមូល ។

**៣ការពារ ៖**

១). ពាក់ម៉ាស់ ៖ ជាពិសេសនៅពេលកំពុងពាក់ម៉ាស់ សូមកុំយកដៃប៉ះផ្ទៃមុខនៃម៉ាស់ ឬ ទាញម៉ាស់ដាក់ក្រោមចង្កា និងត្រូវដូរម៉ាស់ថ្មី នៅពេលវាសើម។

២). លាងដៃ ៖ ឱ្យបានញឹកញាប់ជាមួយសាប៊ូក្នុងរយៈពេល ៤០ វិនាទី ឬ ជាមួយអាល់កុលដែលក្នុងរយៈពេល ២០ វិនាទី។

៣). រក្សាគម្លាតសុវត្ថិភាពបុគ្គលពីមួយម៉ែត្រកន្លះឡើង៖ ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគម្លាតសុវត្ថិភាពនេះ ទោះបីជាបងប្អូន សមាជិកគ្រួសារ និងសាច់ញាតិ ដែលពួកគាត់មានការស្នាក់នៅគេហដ្ឋានផ្សេងពីលោកអ្នក ឬក៏មិត្តភ័ក្រ្តជិតស្និទ្ធក៏ដោយ។

**៣កុំ ៖**

១). កុំទៅកន្លែងមានមនុស្សច្រើន៖ ក្នុងន័យនេះរាប់ទាំងការប្រមូលផ្តុំជួបជុំពិសារអាហារជាលក្ខណៈគ្រួសារ សាច់ញាតិដែលមានការស្នាក់នៅក្នុងគេហដ្ឋានផ្សេងពីលោកអ្នក ឬ មិត្តភ័ក្រ្តជិតស្និទ្ធជាដើម ។

២). កុំទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល និងប្រើម៉ាស៊ីនត្រជាក់ច្រើន

៣). កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា ពេលជួបគ្នា សូម្បីតែសមាជិកគ្រួសារ សាច់ញាតិ ដែលមានការស្នាក់នៅគេហដ្ឋានផ្សេងពីលោកអ្នក ឬ មិត្តភ័ក្រ្តជិតស្និទ្ធ ជាដើម។

- សូមចូលរួមជម្រុញ ក្រើនរំលឹក និងតាមដានដាស់តឿន បុគ្គលខ្លួនឯង សមាជិកគ្រួសារ សាច់ញាតិ អ្នកជិតខាង អ្នកភូមិជាមួយ និងសហគមន៍ជាមួយ ឱ្យអនុវត្តជាប្រចាំថ្ងៃ ឱ្យបានខ្ជាប់ខ្ជួននូវ **៣ការពារ និង៣កុំ** ខាងលើ។

- សូមចូលរួមតាមដាន និងរាយការណ៍ជាបន្ទាន់ជូនដល់អាជ្ញាធរមូលដ្ឋាន ចំពោះអ្នកទើបត្រឡប់មកពីទីកន្លែងដែលមានហានិភ័យខ្ពស់ ឬមកពីក្រៅប្រទេស ដែលទាមទារឱ្យមានការប្រកាន់ខ្ជាប់នូវការធ្វើចត្តាឡីស័កឱ្យបានពេញលេញ និងត្រឹមត្រូវគ្រប់ពេលវេលាទៅតាមការណែនាំរបស់គ្រូពេទ្យ ឬអាជ្ញាធរមានសមត្ថកិច្ច។
- សូមចូលរួមផ្តល់ការអប់រំ និងចែករំលែកនូវចំណេះដឹងដែលខ្លួនបានដឹង និងចេះ បន្តដល់សមាជិកគ្រួសារ សាច់ញាតិ អ្នកជិតខាង អ្នកភូមិជាមួយ និងសហគមន៍ជាមួយ។
- សូមចូលរួម និងរួបរួមគ្នា សហការគ្នា ជាមួយអាជ្ញាធរមូលដ្ឋាន រកដំណោះស្រាយក្នុងតំបន់ ដើម្បីដោះស្រាយបញ្ហាដែលកើតមាននៅក្នុងសហគមន៍របស់ខ្លួនទាក់ទងនិងការអនុវត្តន៍ "៣ការពារ និង៣កុំ" ឱ្យមានប្រសិទ្ធភាព។
- សូមចូលរួមអនុវត្តឱ្យបានតាមការណែនាំ និងវិធានការនានា ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ក្រសួងសុខាភិបាល និងដោយអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ដើម្បីអនុញ្ញាតឱ្យយើងអាចគ្រប់គ្រងសភាពការបានល្អទាន់ពេលវេលា និងអាចបន្តអាជីវកម្ម ព្រមទាំងវិស័យទាំងអស់ និងអាចដំណើរការឡើងវិញបាន ហើយប្រជាពលរដ្ឋអាចប្រកបរបរចិញ្ចឹមជីវិតឡើងវិញប្រកបដោយសុវត្ថិភាព នៅក្នុងបរិបទប្រយុទ្ធនឹងជំងឺកូវីដ-១៩ ទៅតាមបែបរស់នៅធម្មតាក្នុងប្រក្រតីភាពថ្មី។

**ខ. សម្រាប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្តទាំងអស់ ៖**

- ត្រូវចាត់ចែងរៀបចំបន្តធ្វើពិធីយុទ្ធនាការក្នុងខេត្តរៀងៗខ្លួន ដោយមានការចូលរួមពីផ្នែកពាក់ព័ន្ធនានា ដោយធ្វើការផ្សព្វផ្សាយតាមរយៈការផ្សាយតាមឧបករណ៍បំពងសម្លេង ទូងស្គរ ការបិទតាំងរូបភាពផ្ទាំងធំ ចែកចាយខិតប័ណ្ណ ការផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ និងបណ្តាញសង្គម ជូនដល់ប្រជាជន ឲ្យបានឆាប់រហ័សទៅដល់គ្រប់ភូមិគោលដៅ
- បន្តសហការជាមួយដៃគូពាក់ព័ន្ធ សង្គមស៊ីវិល ក្នុងរាជធានី-ខេត្តទាំងអស់ ដើម្បីបោះពុម្ព ចែកចាយ សម្ភារៈអប់រំសុខភាព ឲ្យបានទូលំទូលាយនៅទូទាំងរាជធានី-ខេត្ត ជាពិសេសដល់សហគមន៍ងាយរងគ្រោះ និងសហគមន៍ក្រីក្រជាដើម
- ណែនាំ និងចាត់វិធានការដល់អាជីវកម្មដែលមានហានិភ័យខ្ពស់ដូចជា ក្លឹបកំសាន្ត អាជីវកម្មម៉ាស្សា ហាងលក់និងសេពគ្រឿងស្រវឹង ព្រមទាំងភោជនីយដ្ឋាន ទីកន្លែងលក់អាហារ ទីផ្សារ ផ្សារទំនើប ធនាគារ និងកន្លែងប្រកបអាជីវកម្មផ្សេងៗ ត្រូវពង្រឹង និងយកចិត្តទុកដាក់បន្ថែមទៅលើការអនុវត្តន៍វិធានការសុខាភិបាល ដើម្បីបង្ការការឆ្លងជាយថាហេតុនូវវីរុសកូវីដ-១៩ នៅពេលជួបជាមួយអតិថិជនទូទៅនៅក្នុងទីតាំងអាជីវកម្មរបស់ខ្លួន។ ចាត់វិធានការបិទជាបណ្តោះអាសន្ននូវទីតាំងអាជីវកម្មណាដែលមិនគោរពតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល។
- ណែនាំ និងការចាត់វិធានការតាមដានការអនុវត្តន៍វិធានការសុខាភិបាលនៅតាមសហគមន៍ ដូចជាចាត់តាំងអាជ្ញាធរ ភូមិ ឃុំ ស្រុក និងតំណាងសហគមន៍ ត្រួតពិនិត្យ និងណែនាំការអនុវត្តន៍គម្លាតសុវត្ថិភាពបុគ្គលពីម្នាក់ទៅម្នាក់ឲ្យបានយ៉ាងតិច ១,៥ម៉ែត្រឡើងទៅ នៅតាមទីសាធារណៈនានា។ អនុវត្តគម្លាតសុវត្ថិភាពសង្គមឲ្យបានហ្មត់ចត់ដោយហាមឃាត់ ឬកាត់បន្ថយឲ្យបានជាអតិបរិមា នូវការជួបជុំគ្នាក្នុងសង្គម ដូចជាពិធីរៀបអាពាហ៍ពិពាហ៍ ពិធីបុណ្យនានា ការជួបជុំគ្នាកុះករក្នុងពិធីបុណ្យជាតិ ពិធីបុណ្យសាសនា ពិធីបុណ្យប្រពៃណី ឬពិធីបុណ្យផ្សេងៗ ការប្រគុំតន្ត្រី ការដើរលេងជួបជុំគ្នាច្រើន ការបរិភោគអាហារជាមួយមិត្តភ័ក្តិខាងក្រៅផ្ទះ ការជួបជុំពិធីខួបកំណើត ឬការធ្វើពិធីឡើងផ្ទះក្នុងទ្រង់ទ្រាយធំ ការធ្វើដំណើរកំសាន្តប្រមូលផ្តុំគ្នាច្រើន ជាដើម។
- ណែនាំ និងចាត់វិធានការ ជម្រុញប្រជាជនក្នុងសហគមន៍ឲ្យយកចិត្តទុកដាក់ អនុវត្តអនាម័យជានិច្ច ដោយលាងដៃជាមួយទឹកស្អាត និងសាប៊ូ ឬទឹកអាល់កុល ទឹកដែលលាងដៃ ឲ្យបានញឹកញាប់ ប្រើប្រាស់ម៉ាស់ឲ្យបានត្រឹមត្រូវជាប្រចាំ ប្រើកន្សែង ឬក្រមា ឬក្រដាសជូតមាត់ ដើម្បីខ្ទប់មាត់ និងច្រមុះពេលក្អកកណ្តាស់។
- ណែនាំដល់អ្នកដែលមានហានិភ័យខ្ពស់នៃការចម្លងជំងឺ ដូចជាជនចាស់ជរា ជនដែលមានជំងឺប្រចាំកាយ ស្ត្រីមានផ្ទៃពោះ និងកុមារតូចៗជាដើម ជៀសវាងចេញពីផ្ទះបើមិនចាំបាច់។

**គ. សម្រាប់ ស្ថាប័នពាក់ព័ន្ធនានា វិស័យឯកជន និង អង្គការជាតិ អន្តរជាតិ ៖**

- សូមចូលរួមជួយគាំទ្រ នូវសកម្មភាពរបស់យុទ្ធនាការជាតិនេះ ដោយបន្តធ្វើការផ្សព្វផ្សាយសារយុទ្ធនាការជាតិបានជាប់ជាប្រចាំ តាមគ្រប់មធ្យោបាយដែលមាន ដល់បុគ្គលិកនៃស្ថាប័នរបស់ខ្លួន ។
- សូមធ្វើការតាមដានជាប្រចាំ និងឃ្លាំមើល នូវការអនុវត្តន៍របស់បុគ្គលិកដែលស្ថិតនៅក្រោមឱវាទស្ថាប័នរបស់ខ្លួន ព្រមទាំងរួមគ្នារកដំណោះស្រាយនៅហ្នឹងកន្លែង ដើម្បីបន្តជម្រុញការអនុវត្តន៍វិធានការណ៍សុខាភិបាល និងអន្តរាគមន៍នានាប្រកបដោយប្រសិទ្ធិភាព។
- សូមចូលរួម បន្តផ្តល់ការអប់រំ ជម្រុញ ក្រើនរំលឹក និងដាស់តឿនជាប្រចាំ ដល់បុគ្គលិកដែលស្ថិតនៅក្រោមស្ថាប័នរបស់ខ្លួន អំពីការអនុវត្តន៍ "៣ការពារ និង៣កុំ" ឱ្យមានប្រសិទ្ធភាព។
- ផលិត និងបិទផ្ទាំងរូបភាពទាក់ទងនឹងការបង្ការ និងទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ នៅក្នុងស្ថាប័នរបស់ខ្លួន
- ចាក់មេក្រូផ្សព្វផ្សាយ នូវសារអប់រំ ជាប់ជាប្រចាំ នៅកន្លែងធ្វើការនីមួយៗ។

ក្រសួងសុខាភិបាល និងគណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងអនុគៈណកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ (អ.ប.ទ) សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះការយកចិត្តទុកដាក់ចូលរួមផ្សព្វផ្សាយ ទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ របស់បុគ្គល គ្រួសារ និងសហគមន៍ និងបងប្អូនប្រជាពលរដ្ឋ ស្ថាប័នពាក់ព័ន្ធនានា វិស័យឯកជន និង អង្គការជាតិ អន្តរជាតិ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ទាំងអស់ ហើយក៏សូមអំពាវនាវ ឱ្យមានការចូលរួមអនុវត្តតាមការណែនាំខាងលើនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីរួមចំណែក កាត់ផ្តាច់ខ្សែចម្លង វីរុសកូវីដ-១៩ និងការចម្លងវីរុសកូវីដ-១៩ពីបុគ្គលម្នាក់ទៅម្នាក់ ជាពិសេសត្រូវចូលរួមបញ្ចៀសនូវការរាតត្បាតជាលក្ខណៈទ្រង់ទ្រាយធំ នៅក្នុងប្រទេសកម្ពុជា ដោយសារតែ វីរុសបំប្លែងថ្មីដែលគានេះ ។

ថ្ងៃចន្ទ ៨កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១



ទីស្ដីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្ដេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩